មាតិកា

I-ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

២៩-៨-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៨១២/៧៧២ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក គីម ជុងលី (KIM JONG LEE) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតនៅទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ៦៧៣២

២៩-៨-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៨១២/៧៧៣ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក លី ស៊ូអ៊ីល (LEE SOOIL) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតនៅទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ដោយប្ដូរឈ្មោះជា ភួង សារឿន (PHOUNG SAROEUN) ៦៧៣៣

២៩-៨-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០៨១២/៧៧៤ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់អ្នកស្រី ទ្រូណូវ៉ា ម៉ារីណា (TRUNOVA MARINA) ជនជាតិរុស្ស៊ី សញ្ជាតិរុស្ស៊ី កើតនៅទីក្រុងខាបារ៉ស់ សហព័ន្ធរុស្ស៊ី ដោយប្ដូរឈ្មោះជា ណា ម៉ារី (NA MARY) ៦៧៣៤

II-រាជរដ្ឋាភិបាល

១-អនុក្រឹត្យ

១០-៩-២០១២ -អនុក្រឹត្យលេខ ១៤២ អនក្រ.បក ស្ដីពី ការផ្ទេរឥណទានថវិកា ៦៧៣៥

១១-៩-២០១២ -អនុក្រឹត្យលេខ ១៤៣ អនក្រ.បក ស្ដីពី ការផ្លាស់ប្ដូរចំណាត់ថ្នាក់ប្រើប្រាស់ដីរដ្ឋ ដោយផ្ទេរពីមុខដីបរិវេណអាកាសយានដ្ឋានក្រចេះ ទៅគោលដៅសម្រាប់សាងសង់សាកលវិទ្យាល័យក្រចេះ ៦៧៣៧

១១-៩-២០១២ -អនុក្រឹត្យលេខ ១៤៤ អនក្រ.បកស្ដីពី ការកែសម្រួលអនុក្រឹត្យលេ ១៦០ អនក្រ.បក ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ២០០៩ ស្ដីពី ការបង្កើតប្រសិទ្ធភាពការងារ របស់ក្រុមប្រឹក្សាវិន័យ នៃឧត្ដមក្រុមប្រឹក្សា នៃអង្គចៅក្រម ៦៧៣៩

០៧-៩-២០១២ -អនុក្រឹត្យលេខ ១១៥៤ អនក្រ.តត ស្ដីពី ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ ៦៧៤៦

១០-៩-២០១២ -អនុក្រឹត្យលេខ ១១៥៥ អនក្រ.តត ស្ដីពី ការដាក់មន្ត្រីការទូតជាន់ខ្ពស់ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស ៦៧៤៨

១០-៩-២០១២ -អនុក្រឹត្យលេខ ១១៥៩ អនក្រ.តត ស្ដីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៦៧៥០

១០-៩-២០១២ -អនុក្រឹត្យលេខ ១១៦០ អនក្រ.តត ស្ដីពី ការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ៦៧៥១

១១-៩-២០១២ -អនុក្រឹត្យលេខ ១១៦១ អនក្រ.តត ស្ដីពី ការលុបឈ្មោះមន្ត្រីរាជការ ៦៧៥២
១១-៩-២០១២ -អនុក្រឹត្យលេខ ១១៦២ អនក្រ.តត ស្ដីពី ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ ៦៧៥៤
១១-៩-២០១២ -អនុក្រឹត្យលេខ ១១៦៣ អនក្រ.តត ស្ដីពី ការតែងតាំងមុខតំណែង នាយនគរបាលជាតិ ៦៧៥៥
១១-៩-២០១២ -អនុក្រឹត្យលេខ ១១៦៤ អនក្រ.តត ស្ដីពី ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ ៦៧៥៦
១៣-៩-២០១២ -អនុក្រឹត្យលេខ ១១៦៥ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ៦៧៥៨
១៣-៩-២០១២ -អនុក្រឹត្យលេខ ១១៦៦ អនក្រ.តត ស្ដីពី ការតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីរាជការ ៦៧៦០
១៣-៩-២០១២ -អនុក្រឹត្យលេខ ១១៦៧ អនក្រ.តត ស្ដីពី ការតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីរាជការ ៦៧៦៣
១៣-៩-២០១២ -អនុក្រឹត្យលេខ ១១៦៨ អនក្រ.តត ស្ដីពី ការតម្លើងឋានន្តរស័ក្តិ និង ថ្នាក់មន្ត្រីរាជការ ៦៨១៦
១៣-៩-២០១២ -អនុក្រឹត្យលេខ ១១៦៩ អនក្រ.តត ស្ដីពី ការតម្លើងថ្នាក់មន្ត្រីរាជការ ៦៨១៩
១៣-៩-២០១២ -អនុក្រឹត្យលេខ ១១៧០ អនក្រ.តត ស្ដីពី ការតម្លើងថ្នាក់មន្ត្រីរាជការ ៦៨២១

២~សេចក្ដីសំរេច

១០-៩-២០១២ -សេចក្ដីសំរេចលេខ ៣៦ សសរ ស្ដីពី ការតែងតាំងសមាសភាពគណៈកម្មាធិការអន្តរក្រសួង ដើម្បីសម្របសម្រួល វាយតម្លៃ និងត្រួតពិនិត្យវត្ថុសិល្បៈបុរាណខ្មែរ ដែលត្រូវយកទៅតាំងពិព័រណ៍នៅបរទេស ៦៨២៥
១១-៩-២០១២ -សេចក្ដីសំរេចលេខ ៣៧ សសរ ស្ដីពី ការបង្កើតគណៈកម្មាធិការដឹកនាំត្រួតពិនិត្យឡើងវិញ នូវការអនុវត្តអនុសញ្ញា អ.ស.ប ប្រឆាំងអំពើពុករលួយ (UNCAC) នៅកម្ពុជា ៦៨២៧
១៧-៩-២០១២ -សេចក្ដីសំរេចលេខ ៣៨ សសរ ស្ដីពី ការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល ៦៨៣១

III~ការងារបណ្ដាក្រសួង

ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១៩-៥-២០១១ -លិខិតបញ្ជាក់លេខ ២៦៦២ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឌីនឡី ត្រេឌីត** ៦៨៣២
១៩-៥-២០១១ -លិខិតបញ្ជាក់លេខ ២៦៦៣ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេ វិទ្ធី ឌើលស៍** ៦៨៣៤
១៩-៥-២០១១ -លិខិតបញ្ជាក់លេខ ២៦៦៤ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឌីអេច 3 ខនសាល់ធេន** ៦៨៣៦
១៩-៥-២០១១ -លិខិតបញ្ជាក់លេខ ២៦៦៥ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ថៅវ៉ាស៊ីស សីលូសិន** ៦៨៣៨

២០-៥-២០១១ -លិខិតបញ្ជាក់លេខ ២៦៩១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អេ.ឌី ម៉ាញ្ញូនីង (ខេមបូឌា) ៦៨៤០

២០-៥-២០១១ -លិខិតបញ្ជាក់លេខ ២៦៩៤ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ថេស-អាម (ខេមបូឌា) ខូ អិលធីឌី ៦៨៤២

២០-៥-២០១១ -លិខិតបញ្ជាក់លេខ ២៦៩៥ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ទីហ្វូរ ឡាយសាយអិន (ខេមបូឌា) ៦៨៤៤

២០-៥-២០១១ -លិខិតបញ្ជាក់លេខ ២៦៩៧ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ខេមបូឌាន មូ យាន អ៊ិនវេសមេន ហូលឌីង គ្រុប ៦៨៤៦

២០-៥-២០១១ -លិខិតបញ្ជាក់លេខ ២៦៩៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ថៃលឃ្យូ អ៊ិនធីគ្រេសិន ៦៨៤៨

២០-៥-២០១១ -លិខិតបញ្ជាក់លេខ ២៧០៧ ពណ.ចបព ស្តីពី ការទទួលចុះបញ្ជីនូវការកែប្រែ និង តម្កល់ទុកឯកសារវិសោធនកម្មលើលក្ខន្តិកៈ របស់ក្រុមហ៊ុន ខេមបូឌា ប្រេវេត ផ្លេនីង & ឌីវេឡុបមេន មេនេចមេន (ស៊ីភីភីឌីអឹម) ៦៨៥០

ព្រះរាជក្រឹត្យ

នស/រកត/០៨១២/៧៧២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ញាតូបនីយកម្មដល់លោក **គីម ជុងលី** (KIM JONG LEE) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៦២ នៅទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខៈ ៧៤៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កញ្ញា ឆ្នាំ២០១២
[illegible]រាជរដ្ឋាភិបាល
សយ សុខា

៣រស.១២០៥.៧៧៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១២

ព្រះរាជក្រឹត្យ

នស/រកត/០៨១២/៧៧៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **លី ស៊ូអ៊ីល** (LEE SOOIL) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៦២ នៅទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ដោយប្តូរឈ្មោះជា **ភួង សារឿន** (PHOUNG SAROEUN)។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រស.១២០៧.៧៥០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២

លេខ: ៧៥៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី

ស៊ុយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០៨១២/៧៧៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់អ្នកស្រី **ទ្រូណូវ៉ា ម៉ារីណា** (TRUNOVA MARINA) ជនជាតិរុស្ស៊ី សញ្ជាតិរុស្ស៊ី កើតថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៦៩ នៅទីក្រុងខាបារ៉ូស់ សហព័ន្ធរុស្ស៊ី ដោយប្តូរឈ្មោះជា **ណា ម៉ារី** (NA MARY)។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចរល.១២០៧.៧៥១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២

លេខ: ៧៤៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ កញ្ញា ឆ្នាំ២០១២
អគ្គលេខាធិការរង[illegible]រដ្ឋាភិបាល

សយ សុខា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ :.១៤២...អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥, ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤, ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨, ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦, ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២១១/០១៩, ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០១២

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក, ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក, ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក, ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក, ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឲ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ២៨៧ អនក្រ.បក, ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១១ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០១២

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រេច

មាត្រា១: ត្រូវបានអនុញ្ញាតឲ្យផ្ទេរឥណទានថវិកាចំនួន១ ៩៥៨ ០០០ ០០០រៀល(មួយពាន់ប្រាំបួនរយហាសិបប្រាំបីលានរៀលគត់) ពីជំពូក០៩(ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក៦២ (សេវាខាងក្រៅផ្សេងៗ) ជូនក្រសួងសាធារណការ និងដឹកជញ្ជូន សម្រាប់ការគ្រប់គ្រងឆ្នាំ២០១២។

មាត្រា២: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ទូទាត់បុរេប្រទានចំណាយរៀបចំកិច្ចប្រជុំអាស៊ានក្នុងនាមជាម្ចាស់ផ្ទះក្នុងឆ្នាំ២០១១ ចំនួន០៤លើក និងសម្រាប់ចំណាយក្នុងពិធីសម្ពោធសមិទ្ធិផល និងពិធីបើកការដ្ឋានក្នុងឆមាសទី២ ឆ្នាំ២០១២។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ , ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

បានយកសេចក្តីជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៤៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការផ្លាស់ប្តូរចំណាត់ថ្នាក់ប្រើប្រាស់ដីរដ្ឋ ដោយផ្ទេរពីមុខងារដីបរិវេណអាកាសយានដ្ឋានក្រចេះ ទៅគោលដៅសម្រាប់សាងសង់សាកលវិទ្យាល័យក្រចេះ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ
- យោងតាមតម្រូវការចាំបាច់

ស ម្រេ ច

មាត្រា១:-

ត្រូវបានផ្លាស់ប្តូរចំណាត់ថ្នាក់ប្រើប្រាស់ដីរដ្ឋ ដោយផ្ទេរពីមុខងារដីបរិវេណអាកាសយានដ្ឋានក្រចេះ ទៅគោលដៅសម្រាប់សាងសង់សាកលវិទ្យាល័យក្រចេះ ដែលមានផ្ទៃដីទំហំ ៩៩,០១ ហិកតា ជាក្បាលដីទី១

ស្ថិតនៅផ្នែកខាងត្បូង ផ្លូវជាតិលេខ ៧ ដូចមានប្លង់លេខ ០៨៦៧ /៩៨ ចុះថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ ១៩៩៨ និង សេចក្តីបញ្ជាក់លេខ ៨៤៩ ចណ ក្រច ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ១៩៩៨ របស់អភិបាលខេត្តក្រចេះ ព្រមទាំងមាន និយាមកាដូចខាងក្រោម ÷

C1	E6-14-823	N13-81-685
C2	E6-14-659	N13-81-378
C3	E6-14-438	N13-81-497
C4	E6-14-202	N13-81-056
C5	E6-14-422	N13-80-938
C6	E6-13-831	N13-79-836
C7	E6-14-184	N13-79-647
C8	E6-15-237	N13-81-610

មាត្រា២: -

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៣: -

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និង អភិបាលនៃគណៈអភិបាលខេត្តក្រចេះ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមាន ប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៥៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកែសម្រួលអនុក្រឹត្យលេខ ១៦០ អនក្រ.បក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពីការបង្កើនប្រសិទ្ធភាពការងារ របស់ក្រុមប្រឹក្សាវិន័យ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ០៩០៨/ ១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស/ ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ០៨០៧/ ០២៤ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពនៃសាលាជម្រះក្តី
- បានឃើញព្រះរាជក្រមលេខ ០៩/ នស/ ៩៤ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ០១៩៦/ ០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ០៩០៤/ ២៨៤ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ដែលនិរាករណ៍ព្រះរាជក្រឹត្យលេខ នស/ រកត/ ០៣៩៩/ ៧២ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ០៦០២/ ១៥៨ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០២ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ០៣០៩/ ៣៥៨ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩ ស្តីពីការកែសម្រួលមាត្រា១ និងមាត្រា៦ នៃព្រះរាជក្រឹត្យលេខ នស/ រកត/ ០៦០២/ ១៥៨ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០២ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ១៦០ អនក្រ.បក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពីការបង្កើនប្រសិទ្ធភាពការងាររបស់ក្រុមប្រឹក្សាវិន័យ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានឃើញសេចក្តីសម្រេចលេខ ០៣ សសរ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើតក្រុមការងាររបស់ក្រសួងយុត្តិធម៌ ក្នុងការងារនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- យោងតាមសំណើរបស់សហប្រធាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

សម្រេច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

មាត្រា១.

អនុក្រឹត្យនេះមានគោលដៅកំណត់ អំពីយន្តការបង្កើនប្រសិទ្ធភាពការងាររបស់ក្រុមប្រឹក្សាវិន័យ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម អំពីតួនាទី ភារកិច្ច និងសមាសភាព ព្រមទាំងដំណើរការនៃយន្តការនេះ ក្នុងគោលបំណងជួយក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងការបំពេញតួនាទី

របស់ខ្លួនជាស្ថាប័នតែមួយគត់ដែលមានសមត្ថកិច្ចរំលឹក ដាស់តឿន កែលំអ ឬចាត់ការ តាមនីតិវិធីស៊ើបអង្កេត ស្រាវជ្រាវ និងដាក់ឬមិនដាក់វិន័យចៅក្រម និងព្រះរាជអាជ្ញា ស្របតាមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

ជំពូកទី២

យន្តការបង្កើនប្រសិទ្ធភាពការងាររបស់ក្រុមប្រឹក្សាវិន័យ

នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

មាត្រា២.

ត្រូវបានបង្កើតយន្តការមួយដើម្បីបង្កើនប្រសិទ្ធភាពរបស់ក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដែលមានឈ្មោះថា «អង្គភាពអធិការកិច្ចនៃក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម» ហៅកាត់ថា (អ.ក.វ) ស្ថិតក្រោមការដឹកនាំ និងបញ្ជាផ្ទាល់ពីប្រធានតុលាការកំពូល ឬអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ដែលជាប្រធានក្រុមប្រឹក្សាវិន័យ អាស្រ័យទៅតាមករណីទាក់ទងនឹងចៅក្រម ឬព្រះរាជអាជ្ញា។

ជំពូកទី៣

តួនាទី ភារកិច្ច និងសមាសភាព

របស់អង្គភាពអធិការកិច្ចនៃក្រុមប្រឹក្សាវិន័យ (អ.ក.វ)

មាត្រា៣.

អង្គភាពអធិការកិច្ចនៃក្រុមប្រឹក្សាវិន័យ (អ.ក.វ) មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ទទួលពាក្យបណ្តឹង និងតាមដានព័ត៌មានទាំងឡាយពាក់ព័ន្ធទៅនឹងចៅក្រម ព្រះរាជអាជ្ញា និងរាយការណ៍ជូនប្រធានក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- រំលឹក ដាស់តឿនចៅក្រម ព្រះរាជអាជ្ញា ឱ្យអនុវត្តក្រមសីលធម៌ចៅក្រមឱ្យបានត្រឹមត្រូវ
- ចុះធ្វើអធិការកិច្ចជាប្រចាំស្វែងយល់អំពីការលំបាក ការងាយស្រួល ចំណុចខ្វះខាត ចំណុចល្អ ដែលកំពុងកើតមានច្រើននៅតាមតុលាការនានា ណែនាំរបៀបរបបការងារ និងធ្វើ

របាយការណ៍លើកសំណើរវិធានការជូនប្រធានក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមចាត់ការជាបន្ត

- ចុះស៊ើបអង្កេតករណីមិនប្រក្រតីតាមបណ្តាសាលាជម្រះក្តីនៅក្នុងព្រះរាជាណាចក្រកម្ពុជាតាមពាក្យបណ្តឹង
- ធ្វើរបាយការណ៍ជូនប្រធានក្រុមប្រឹក្សាវិន័យ ដោយលើកនូវអង្គហេតុ អង្គច្បាប់ និងធាតុចេតនា របស់ចៅក្រម ឬព្រះរាជអាជ្ញា ស្ថានភាពផ្សេងៗដែលពាក់ព័ន្ធនឹងការសម្រេចរបស់ចៅក្រម ព្រះរាជអាជ្ញានោះ និងលើកមតិដោះស្រាយ
- ចាត់ការឱ្យថតចម្លងឯកសារដែលពាក់ព័ន្ធនឹងចៅក្រម ឬព្រះរាជអាជ្ញា ដែលត្រូវគេប្តឹងជូនសមាជិកក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- ធ្វើទំនាក់ទំនងផ្នែករដ្ឋបាលជាមួយក្រសួងយុត្តិធម៌ និងក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀត
- រៀបចំរាល់កិច្ចប្រជុំក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ធ្វើកំណត់ហេតុអង្គប្រជុំ គ្រប់គ្រងឯកសារ និងពាក្យបណ្តឹងនានា
- ធ្វើរបាយការណ៍បូកសរុបប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ជូនក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលប្រធានក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមប្រគល់ឱ្យ។

មាត្រា៤.

អង្គភាពអធិការកិច្ចនៃក្រុមប្រឹក្សាវិន័យ (អ.ក.វ) មានសមាសភាពដូចតទៅ៖

១-ឯកឧត្តម **ជីវ កេង**	សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម	ជា ប្រធាន
២-ឯកឧត្តម **ប៉ាល់-ចន្ទសារា**	តំណាងក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌	ជា អនុប្រធាន
៣-លោក **សេង ប៊ុនឃាង**	ព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល	ជា អនុប្រធាន
៤-ឯកឧត្តម **កើត រិទ្ធ**	អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌	ជា សមាជិក
៥-លោក **ជ័យ សុផល**	ចៅក្រមតុលាការកំពូល	ជា សមាជិក
៦-លោក **ច័ន្ទ រស្មី**	ចៅក្រមតុលាការកំពូល	ជា សមាជិក

៧-លោក **ប៉ុល សំអឿន**	ចៅក្រមសាលាឧទ្ធរណ៍	ជា សមាជិក
៨-លោក **ប្លង់ សំណាង**	ចៅក្រមសាលាឧទ្ធរណ៍	ជា សមាជិក
៩-លោក **ហ៊ាន រិទ្ធ**	ព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍	ជា សមាជិក
១០-លោក **អឿង សៀង**	អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ	ជា សមាជិក
១១-លោក **សេង នាង**	ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ	ជា សមាជិក
១២-លោក **ឌុច គឹមសន**	ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ	ជា សមាជិក
១៣-លោក **យូ ម៉ិនណា**	ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ	ជា សមាជិក
១៤-លោកស្រី **ចាំង ស៊ីណាត**	ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ	ជា សមាជិកា
១៥-លោក **ហ្វួត ឧុទ្ធី**	ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តកំពង់ចាម	ជា សមាជិក
១៦-លោក **កើត វណ្ណារ៉េត**	ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តព្រៃវែង	ជា សមាជិក
១៧-លោក **សុខ រឿន**	ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ	ជា សមាជិក
១៨-លោក **មាស ច័ន្ទពិសិដ្ឋ**	ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ	ជា សមាជិក
១៩-អ្នកស្រី **អ៊ុំ រមនា**	ក្រឡាបញ្ជីមហាអយ្យការអមតុលាការកំពូល	ជា លេខាធិការ
២០-កញ្ញា **ហេង មុន្នីរតា**	នាយកក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ	ជា លេខាធិការ
២១-លោក **អ៊ុំ វ៉ន**	ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ	ជា ជំនួយការ
២២-លោក **ហេង ធីរៈ**	ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ	ជា ជំនួយការ

ក្នុងការបំពេញបេសកកម្មរបស់ខ្លួន អង្គភាពអធិការកិច្ចនៃក្រុមប្រឹក្សាវិន័យ (អ.ក.វ) ប្រើប្រាស់នូវមន្ត្រីដូចខាងក្រោម ជាជំនួយការៈ

១-មន្ត្រីនៃក្រុមការងាររបស់ក្រសួងយុត្តិធម៌ក្នុងការងារនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ហៅកាត់ថា «ក្រុមការងារ ក.យ.ឧ.ក្រ.ច» សម្រាប់ជំនួយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

២-ចៅក្រម ឬព្រះរាជអាជ្ញាផ្សេងទៀតតាមការចាំបាច់ក្រោយពីបានការយល់ព្រមពីប្រធានក្រុមប្រឹក្សាវិន័យលើសំណើរបស់ប្រធានអង្គភាពអធិការកិច្ចនៃក្រុមប្រឹក្សាវិន័យ (អ.ក.វ)។

ក្រៅពីនេះ អង្គភាពអធិការកិច្ចនៃក្រុមប្រឹក្សាវិន័យ (អ.ក.វ) អាចសុំកិច្ចសហការពីមន្ត្រីនគរបាល ដែលជានគរបាលជាតិ កងរាជអាវុធហត្ថ និងមន្ត្រីមានសមត្ថកិច្ចនៃក្រសួងស្ថាប័នពាក់ព័ន្ធ។

ជំពូកទី៤

ដំណើរការនៃអង្គភាពអធិការកិច្ចនៃក្រុមប្រឹក្សាវិន័យ

មាត្រា៥.

អង្គភាពអធិការកិច្ចនៃក្រុមប្រឹក្សាវិន័យ (អ.ក.វ) មានទីតាំងនៅអាគារឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ អង្គភាពនេះបើកការប្រជុំរបស់ខ្លួនតាមការកោះអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានមានសិទ្ធិកោះអញ្ជើញ។

ប្រធានអង្គភាពអធិការកិច្ចនៃក្រុមប្រឹក្សាវិន័យ (អ.ក.វ) មានសិទ្ធិអញ្ជើញ ចៅក្រម ព្រះរាជអាជ្ញា ភាគី សាក្សី ឬមន្ត្រីក្រសួងស្ថាប័នពាក់ព័ន្ធចូលរួមប្រជុំទាក់ទងនឹងពាក្យបណ្តឹង។

អង្គភាពអធិការកិច្ចនៃក្រុមប្រឹក្សាវិន័យ (អ.ក.វ) ចុះធ្វើអធិការកិច្ចមួយដងក្នុង១ខែយ៉ាងតិច។

មាត្រា៦.

ក្រុមប្រឹក្សាវិន័យនៃឧត្តមប្រឹក្សានៃអង្គចៅក្រម ត្រូវដោះស្រាយរាល់ពាក្យបណ្តឹងឱ្យទាន់ពេលវេលាប្រកបដោយយុត្តិធម៌ និងតម្លាភាព។

នីតិវិធីនៃការទទួល និងដោះស្រាយពាក្យបណ្តឹងត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់អង្គភាពអធិការកិច្ចនៃក្រុមប្រឹក្សាវិន័យ (អ.ក.វ)។

មាត្រា៧.

អង្គភាពអធិការកិច្ចនៃក្រុមប្រឹក្សាវិន័យ (អ.ក.វ) មានសិទ្ធិប្រើប្រាស់ត្រារបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមក្នុងការបំពេញភារកិច្ច។

មាត្រា៨.

ថវិកាសម្រាប់ដំណើរការការងាររបស់អង្គភាពអធិការកិច្ចនៃក្រុមប្រឹក្សាវិន័យ(អ.ក.វ) ត្រូវប្រើប្រាស់ថវិកាសម្រាប់ដំណើរការការងាររបស់ក្រុមជំនួយការក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដូចមានចែងក្នុងស.ជ.ណ លេខ០៩ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១១។

ជំពូកទី៥
អវសានបញ្ញត្តិ

មាត្រា៩.

អនុក្រឹត្យលេខ ១៦០ អនក្រ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៩ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា១០.

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហប្រធានក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុងមាត្រា៩ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្ដីជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

សហប្រធានក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

សុខ អាន **ឌិត មុន្ទី**

ឧបនាយករដ្ឋមន្ត្រី ប្រធានតុលាការកំពូល

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី

<u>កន្លែងទទួល:</u>

-ក្រសួងព្រះបរមរាជវាំង
-ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេច នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-តុលាការកំពូល
-សាលាឧទ្ធរណ៍
-សាលាដំបូងរាជធានី-ខេត្ត
-ដូចមាត្រា១០
-រាជកិច្ច

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១១៥៤ .អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការដំឡើងឋានន្តរស័ក្តិនាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ៖

១- លោកវរសេនីយ៍ទោ **ឈី ជាង** អត្តលេខ ៦២៤៨៤

២- លោកវរសេនីយ៍ទោ **ហ៊ែល ធីរិទ្ធ** អត្តលេខ ៦៧០០៦

៣- លោកវរសេនីយ៍ទោ **សាយ រិទ្ធីស័ក្តិ** អត្តលេខ ៥៣៩៩៥

៤- លោកវរសេនីយ៍ទោ **ឡេង គីមហុង** អត្តលេខ ៥៧៣១៧

៥- លោកវរសេនីយ៍ទោ **អ៊ូ សាធី** អត្តលេខ ០៥៨៤៨

៦- លោកវរសេនីយ៍ទោ **សោម ប្រាថ្នា** អត្តលេខ ៥៤១៨៨

៧- លោកវរសេនីយ៍ទោ **ឆន់ ម៉ុនថុល** អត្តលេខ ២០៤៣៨

៨- លោកវរសេនីយ៍ទោ **ម៉ែន ម៉ូរ័ត្ន** អត្តលេខ ០៦៨៥៣

៩- លោកវរសេនីយ៍ទោ **ឡុង ម៉ូនីកា** អត្តលេខ ៥៥៦១០

១០- លោកវរសេនីយ៍ទោ **ចេង បុញ្ញរិទ្ធ** អត្តលេខ ០៥៨៣៤

១១- លោកវរសេនីយ៍ទោ **ពេជ ឃីម** អត្តលេខ ៥៦២៧៨

១២- លោកវរសេនីយ៍ទោ **ទូច សុគា** អត្តលេខ ៦៨១៩៥ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធនិងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី ខែ ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១១៥៥ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការដាក់មន្ត្រីការទូតជាន់ខ្ពស់ឲ្យស្ថិតនៅក្នុងភាពទំនេរ
គ្មានបៀវត្ស

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានឃើញអនុក្រឹត្យលេខ១១៦ អនក្រ.កត ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការដាក់មន្ត្រីរាជការស៊ីវិលឲ្យស្ថិតនៅក្នុងភាពទំនេរ គ្មានបៀវត្ស
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

សម្រេច

មាត្រា ១ .- ត្រូវបានដាក់លោក **អេង ហ៊ុន** មន្ត្រីការទូតជាន់ខ្ពស់របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឲ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្សរយៈពេល១ ឆ្នាំ គិតពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ ២០១២ ដល់ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០១៣។

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>*កន្លែងទទួល*</u>

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ- កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១៥៩ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការក្រសួងសុខាភិបាល ចំនួន០៤រូប ដែលមានស្នាដៃល្អក្នុងការសាងសង់អគារមណ្ឌលសុខភាពបឹងធំ ស្ថិតនៅភូមិខ្ចៅ សង្កាត់បឹងធំ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដូចមានរាយនាមខាងក្រោម៖

ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ:

-លោកវេជ្ជបណ្ឌិត **អ៊ឹម សុនាត** ប្រធានការិយាល័យសុខាភិបាល ស្រុកប្រតិបត្តិខាងលិច

ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា:

១-លោក **យឹម សំអាង** ប្រធានការិយាល័យរដ្ឋបាល-បុគ្គលិក

២-លោក **តុប ប៊ុនធី** ប្រធានការិយាល័យគណនេយ្យ-ហិរញ្ញវត្ថុ

គ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ:

-លោកវេជ្ជបណ្ឌិត **ហែម ចាន់យុទ្ធី** អនុប្រធានការិយាល័យសុខាភិបាល ស្រុកប្រតិបត្តិខាងលិច

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១[illegible] ខែ កញ្ញា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១១៦០ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនបណ្ឌិត្យសភាតម្រួតប្រជាជនវៀតណាម ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការ លើវិស័យបណ្តុះបណ្តាលធនធានមនុស្សក្នុងជួរកងកម្លាំងនគរបាលជាតិកម្ពុជា ។

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការព្រឹទ្ធសភា
- -អគ្គលេខាធិការរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និង មាត្រា ២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១១៦១ .អនុក្រ.បក

អនុក្រឹត្យ
ស្តីពី
ការលុបឈ្មោះមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសាធារណការ និង ដឹកជញ្ជូន
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ០២ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- យោងតាមសំណើរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សម្រេច

មាត្រា ១ : ត្រូវបានលុបឈ្មោះមន្ត្រីរាជការចំនួន ០១ រូប ក្នុងឋានន្តរសក្តិវរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួងសាធារណការ និងដឹកជញ្ជូន ដោយសារអវត្តមានគ្មានមូលហេតុ ដូចមានខាងក្រោម៖

ល.រ	គោត្តនាម និង នាម	ភេទ	ថ្ងៃខែឆ្នាំកំណើត	មុខតំណែង	ឋានន្តរសក្តិ និង ថ្នាក់	ថ្ងៃខែឆ្នាំ លុបឈ្មោះ
១	**សេខ សេដ្ឋា**	ប	០១-០៥-១៩៦០	អតីតប្រធាន នាយកដ្ឋាន បុគ្គលិក-ធនធានមនុស្ស	វរមន្ត្រី ថ្នាក់លេខ ៨	០១-០៧-២០១២

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u>

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១៥២ អនក្រ.បក

អនុក្រឹត្យ

ស្ដីពី

ការដាក់ឲ្យមន្ត្រីរាជការចូលនិវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៨០ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ២០០២ ស្ដីពីការគ្រប់គ្រងដំណើរការ នៃការដាក់មន្ត្រីរាជការស៊ីវិលឲ្យចូលនិវត្តន៍តាមអាយុ តាមប្រព័ន្ធព័ត៌មានវិទ្យា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានដាក់ឲ្យលោក **ហាក់ ម៉ូចសេខ** អភិបាលស្រុកបារាយណ៍ ខេត្តកំពង់ធំ ចូលនិវត្តន៍ចាប់ពីថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០១២ តទៅ ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និងមាត្រា ៣
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១៤៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការតែងតាំងមុខតំណែងនាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១២ ស្តីពីការបង្កើតនាយកដ្ឋានកិច្ចការប៉ុស្តិ៍នគរបាលរដ្ឋបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងមុខតំណែងលោកវរសេនីយ៍ឯក **ឃឹម សំណាង** អត្តលេខ ០៣៧៩ ជាប្រធាននាយកដ្ឋានកិច្ចការប៉ុស្តិ៍នគរបាលរដ្ឋបាល នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១១៦៤.អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការដំឡើងឋានន្តរស័ក្តិនាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ៖

១- លោកវរសេនីយ៍ទោ **ហង្ស សេរីឧត** អត្តលេខ ០៣០០១

២- លោកវរសេនីយ៍ទោ **ឈឹម ច័ន្ទសុខ** អត្តលេខ ០១៧២៩

៣- លោកវរសេនីយ៍ទោ **លាន ចាំមម៉ារ៉ាឌី** អត្តលេខ ១៥៦៥៦

៤- លោកវរសេនីយ៍ទោ **ហាច់ សុគន្ធវណ្ណា** អត្តលេខ ០១៩០៥ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធនិងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួលៈ
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១១៦៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយ ស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់ គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.

ត្រូវបានបំពាក់មេដាយ **ស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនដល់សប្បុរសជន និងនាយនគរបាលជាតិចំនួន ៣១ នាក់ ដែលមានទឹកប្រាក់ចំនួន ១១០.០២៩,៦០ ដុល្លា (មួយរយដប់ពាន់ ម្ភៃប្រាំបួន ដុល្លា និង ហុកសិបសេន) ដើម្បីកសាងអធិការដ្ឋាននគរបាលស្រុកវ៉ារិន និងប៉ុស្តិ៍នគរបាលរដ្ឋបាលចំនួន ១២ នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយ មាស ស្ថាបនាជាតិ

- លោវរសេនីយ៍ត្រី តូច សាកល អត្តលេខ ០៣៦៥៨ អធិការនគរបាលស្រុកជីក្រែង ថវិកាចំនួន ១០.០០០ ដុល្លា

ខ-មេដាយ ប្រាក់ ស្ថាបនាជាតិ

១- លោវរសេនីយ៍ឯក ភឹង ចិន្តាឫទ្ធិ អត្តលេខ ០៣៦៧១ ស្នងការរងនគរបាលខេត្តសៀមរាប ថវិកាចំនួន ៥.០២៩,៦០ ដុល្លា

២- លោកអនុសេនីយ៍ទោ ហួត គឹមធន អត្តលេខ ១៣៦៧១ នាយប៉ុស្តិ៍ នៃអធិការដ្ឋាននគរបាលស្រុកអង្គរធំ ថវិកាចំនួន ៥.០០០ ដុល្លា

៣- លោកអនុសេនីយ៍ទោ ជៀប រក្សា អត្តលេខ ១៣៦៣៦ នាយប៉ុស្តិ៍ នៃអធិការដ្ឋាននគរបាលស្រុកបន្ទាយស្រី ថវិកាចំនួន ៥.០០០ ដុល្លា

៤- លោកអនុសេនីយ៍ទោ សាម សុផល អត្តលេខ ១៣៥៨៩ នាយប៉ុស្តិ៍ នៃអធិការដ្ឋាននគរបាលស្រុកប្រាសាទបាគង ថវិកាចំនួន ៥.០០០ ដុល្លា

៥- លោកអនុសេនីយ៍ទោ ឡា សុផារ៉ាត់ អត្តលេខ ១៣៥៩២ នាយប៉ុស្តិ៍ នៃអធិការដ្ឋាននគរបាលស្រុកប្រាសាទបាគង ថវិកាចំនួន ៥.០០០ ដុល្លា

គ-មេដាយ សំរិទ្ធ ស្ថាបនាជាតិ

១- លោកវរសេនីយ៍ត្រី ចៅ ម៉ៅរីរៈ អត្តលេខ ១០៥៣៨ នាយការិយាល័យអន្តោប្រវេសន៍ ថវិកាចំនួន ៣.០០០ ដុល្លា

២- លោកវរសេនីយ៍ត្រី ចាន់ សារ៉េន អត្តលេខ ០៣៦៥៦ អធិការនគរបាលស្រុកក្រឡាញ់ ថវិកាចំនួន ៣.០០០ ដុល្លា

៣- លោកវរសេនីយ៍ត្រី អ៊ិយ វណ្ណា អត្តលេខ ០៣៦៦១ អធិការនគរបាលស្រុកបន្ទាយស្រី ថវិកាចំនួន ៣.០០០ ដុល្លា

៤- លោកវរសេនីយ៍ត្រី ណុប សារ៉ាក់ អត្តលេខ ២៩៧២៧ អធិការនគរបាលស្រុកវ៉ារិន ថវិកាចំនួន ៣.០០០ ដុល្លា

៥- លោកវរសេនីយ៍ត្រី ទិត្យ ណារ៉ុង អត្តលេខ ០៤០៤៨ អធិការនគរបាលស្រុកអង្គរធំ ថវិកាចំនួន ៣.០០០ ដុល្លា

៦- លោកអនុសេនីយ៍ឯក សុខ សុទ្ធាវុធ អត្តលេខ ០៤០០៦ អធិការរងនគរបាលស្រុកជីក្រែង ថវិកាចំនួន ៣.០០០ ដុល្លា

៧- លោកអនុសេនីយ៍ឯក ស្រី សំអុល អត្តលេខ ០៤០០៩ អធិការរងនគរបាលស្រុកជីក្រែង ថវិកាចំនួន ៣.០០០ ដុល្លា

៨- លោកអនុសេនីយ៍ទោ នី សារុន អត្តលេខ ២០១៥៤ នាយប៉ុស្តិ៍ នៃអធិការដ្ឋាននគរបាលស្រុកវ៉ារិន ថវិកាចំនួន ៣.០០០ ដុល្លា

៩- លោកអនុសេនីយ៍ទោ ពាំ ពឹង អត្តលេខ ២០២៤១ នាយប៉ុស្តិ៍ នៃអធិការដ្ឋាននគរបាលស្រុកវ៉ារិន ថវិកាចំនួន ៣.០០០ ដុល្លា

១០- លោកអនុសេនីយ៍ទោ ឃាញ សុវណ្ណារ៉ា អត្តលេខ ១៣៦១៤ នាយប៉ុស្តិ៍ នៃអធិការដ្ឋាននគរបាលស្រុកជីក្រែង ថវិកាចំនួន ៣.០០០ ដុល្លា

១១- លោកអនុសេនីយ៍ទោ ស៊ុន សារឿន អត្តលេខ ១៣៦០៩ នាយប៉ុស្តិ៍ នៃអធិការដ្ឋាននគរបាលស្រុកជីក្រែង ថវិកាចំនួន ៣.០០០ ដុល្លា

១២- លោកអនុសេនីយ៍ទោ គីម សាន់ អត្តលេខ ១៣៥៥៦ នាយប៉ុស្តិ៍ នៃអធិការដ្ឋាននគរបាលស្រុកស្រីស្នំ ថវិកាចំនួន ៣.០០០ ដុល្លា

១៣- លោកអនុសេនីយ៍ទោ ប៉ុល ឃ្លី អត្តលេខ ២០២០៨ នាយប៉ុស្តិ៍ នៃអធិការដ្ឋាននគរបាលស្រុកក្រឡាញ់ ថវិកាចំនួន ៣.០០០ ដុល្លា

១៤- លោកអនុសេនីយ៍ទោ ចាប សារួន អត្តលេខ ១៣៦៤៤ នាយប៉ុស្តិ៍ នៃអធិការដ្ឋាននគរបាលស្រុកក្រឡាញ់ ថវិកាចំនួន ៣.០០០ ដុល្លា

១៥- លោកអនុសេនីយ៍ទោ និត សុផេង អត្តលេខ ២០២០៤ នាយប៉ុស្តិ៍ នៃអធិការដ្ឋាននគរបាលស្រុកក្រឡាញ់ ថវិកាចំនួន ៣.០០០ ដុល្លា

១៦- លោកអនុសេនីយ៍ត្រី ខ្វែក ចំរើន អត្តលេខ ២០១៨៦ នាយប៉ុស្តិ៍ នៃអធិការដ្ឋាននគរបាលស្រុកពួក ថវិកាចំនួន ៣.០០០ ដុល្លា

១៧- លោកអនុសេនីយ៍ត្រី ឯក សំ អត្តលេខ ២៩៩៨៣ នាយរងប៉ុស្តិ៍ នៃអធិការដ្ឋាននគរបាលស្រុកក្រឡាញ់ ថវិកាចំនួន ៣.០០០ ដុល្លា

១៨- លោកអនុសេនីយ៍ត្រី សេក ប៊ុនឿន អត្តលេខ ២០២០៥ នាយរងប៉ុស្តិ៍ នៃអធិការដ្ឋាននគរបាលស្រុកក្រឡាញ់ ថវិកាចំនួន ៣.០០០ ដុល្លា

១៩- លោកព្រិន្ទបាលឯក ជា ប៊ុនលី អត្តលេខ ៤៥១៤៥ នាយរងប៉ុស្តិ៍ នៃអធិការដ្ឋាននគរបាលស្រុកប្រាសាទបាគង ថវិកាចំនួន ៣.០០០ ដុល្លា

២០- លោកព្រិន្ទបាលឯក រស់ រឿយ អត្តលេខ ២៩៩៩១ មន្ត្រីប៉ុស្តិ៍ នៃអធិការដ្ឋាននគរបាលស្រុកក្រឡាញ់ ថវិកាចំនួន ៣.០០០ ដុល្លា

២១- លោកព្រិន្ទបាលទោ ស៊ាន សាង អត្តលេខ ៤៥៤៣២ នាយរងប៉ុស្តិ៍ នៃអធិការដ្ឋាននគរបាលស្រុកស្រីស្នំ ថវិកាចំនួន ៣.០០០ ដុល្លា

២២- លោកពលបាលឯក ញ៉ែប សុជាវិទូ អត្តលេខ ៥៣៨៩៧ នាយរងប៉ុស្តិ៍ នៃអធិការដ្ឋាននគរបាលស្រុកប្រាសាទបាគង ថវិកាចំនួន ៣.០០០ ដុល្លា

២៣- លោកពលបាលឯក ផាំ ពី អត្តលេខ ៦១៤០៤ នាយរងប៉ុស្តិ៍ នៃអធិការដ្ឋាននគរបាលស្រុកក្រឡាញ់ ថវិកាចំនួន ៣.០០០ ដុល្លា

២៤- លោកពលបាលទោ ថ្លាង សេងគា អត្តលេខ ៦១៥០៣ នាយរងប៉ុស្តិ៍ នៃអធិការដ្ឋាននគរបាលស្រុកក្រឡាញ់ ថវិកាចំនួន ៣.០០០ ដុល្លា

២៥- លោក ជូ គីមយុង ម្ចាស់ហាងលក់ពូក-ខ្នើយ SAPSA BEDDING ថវិកាចំនួន ៣.០០០ ដុល្លា

មាត្រា ២ .

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែកញ្ញា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល ៖

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១១៦ អនក្រ.បក

អនុក្រឹត្យ
ស្ដីពី
ការតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យ ប្រើច្បាប់ ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ ស្ដីពីការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ ស្ដីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែល ប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែល ប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥២ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្ដីពី លក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៥ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- យោងតាមសំណើរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សម្រេច

មាត្រា ១ : ត្រូវបានតាំងស៊ប់ក្នុងក្របខ័ណ្ឌ ជូនមន្ត្រីរាជការរបស់ក្រសួង ស្ថាប័ន ចំនួន ២៦ រូប ទៅក្នុងឋានន្តរសក្តិមន្ត្រីបច្ចេកទេសមធ្យម នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម ដូចមាននាមខាងក្រោមៈ

ល.រ	នាម និង គោត្តនាម	ភេទ	ថ្ងៃខែឆ្នាំកំណើត	ឋានន្តរសក្តិ	ថ្នាក់
ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា					
តាំងស៊ប់ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១២ តទៅ					
១	**ព្រំ សុវណ្ណា**	ប	១៤-១០-១៩៦៩	មន្ត្រីបច្ចេកទេសមធ្យម	ថ្នាក់លេខ **១៤**
២	**គី ម៉ី**	ប	០៥-០១-១៩៧០	មន្ត្រីបច្ចេកទេសមធ្យម	ថ្នាក់លេខ **១៤**
៣	**នូ ស៊ីឡុន**	ស	២១-០៩-១៩៧៣	មន្ត្រីបច្ចេកទេសមធ្យម	ថ្នាក់លេខ **១៤**
៤	**ហាក់ អេង**	ប	០២-០២-១៩៦០	មន្ត្រីបច្ចេកទេសមធ្យម	ថ្នាក់លេខ **១៤**
៥	**ស៊ាម សុភេរ៉ូ**	ប	២០-១២-១៩៨០	មន្ត្រីបច្ចេកទេសមធ្យម	ថ្នាក់លេខ **១៤**
៦	**ស៊ីន សុគន្ធី**	ស	០៨-០៥-១៩៧៦	មន្ត្រីបច្ចេកទេសមធ្យម	ថ្នាក់លេខ **១៤**
៧	**កែវ មុនី**	ស	០៧-០៥-១៩៧៣	មន្ត្រីបច្ចេកទេសមធ្យម	ថ្នាក់លេខ **១៤**
៨	**ជួប ជតា**	ស	០៧-១២-១៩៧៥	មន្ត្រីបច្ចេកទេសមធ្យម	ថ្នាក់លេខ **១៤**
៩	**ហ៊ុន រ៉ាត**	ស	១៧-០៤-១៩៧៧	មន្ត្រីបច្ចេកទេសមធ្យម	ថ្នាក់លេខ **១៤**
១០	**ខួន តា**	ប	១០-០៩-១៩៧៥	មន្ត្រីបច្ចេកទេសមធ្យម	ថ្នាក់លេខ **១៤**
១១	**ស៊ុន ពៅ**	ប	០១-០៣-១៩៦៥	មន្ត្រីបច្ចេកទេសមធ្យម	ថ្នាក់លេខ **១៤**
១២	**សេង សាយ**	ប	១៧-០៨-១៩៧១	មន្ត្រីបច្ចេកទេសមធ្យម	ថ្នាក់លេខ **១៤**
១៣	**ម៉ៅ សុផាន**	ប	១៤-១០-១៩៦៩	មន្ត្រីបច្ចេកទេសមធ្យម	ថ្នាក់លេខ **១៤**
១៤	**យស ស៊ីណេត**	ស	០៥-១១-១៩៦៧	មន្ត្រីបច្ចេកទេសមធ្យម	ថ្នាក់លេខ **១៤**
១៥	**ហេង សុខឡេង**	ប	០១-០៣-១៩៦៦	មន្ត្រីបច្ចេកទេសមធ្យម	ថ្នាក់លេខ **១៤**
១៦	**សាយ គីមសាន**	ប	០២-០៦-១៩៦០	មន្ត្រីបច្ចេកទេសមធ្យម	ថ្នាក់លេខ **១៤**
១៧	**ជួង ជេដ្ឋា**	ប	១០-០១-១៩៧៣	មន្ត្រីបច្ចេកទេសមធ្យម	ថ្នាក់លេខ **១៤**
១៨	**ជុន ខាន្ទី**	ប	០១-០១-១៩៦៤	មន្ត្រីបច្ចេកទេសមធ្យម	ថ្នាក់លេខ **១៤**
១៩	**ខឹម តិរម្សី**	ប	០១-០៤-១៩៦២	មន្ត្រីបច្ចេកទេសមធ្យម	ថ្នាក់លេខ **១៤**
២០	**កង សាម៉ន**	ប	០៦-០៦-១៩៦៩	មន្ត្រីបច្ចេកទេសមធ្យម	ថ្នាក់លេខ **១៤**
២១	**ឡុត ធីណេត**	ស	១៩-០៩-១៩៧៨	មន្ត្រីបច្ចេកទេសមធ្យម	ថ្នាក់លេខ **១៤**
២២	**យុត រិទ្ធី**	ប	១០-០១-១៩៧២	មន្ត្រីបច្ចេកទេសមធ្យម	ថ្នាក់លេខ **១៤**
២៣	**អ៊ុច ឃាម**	ប	០២-០៤-១៩៧៥	មន្ត្រីបច្ចេកទេសមធ្យម	ថ្នាក់លេខ **១៤**
២៤	**ទ័រ រមេលី**	ស	០៧-០៧-១៩៨០	មន្ត្រីបច្ចេកទេសមធ្យម	ថ្នាក់លេខ **១៤**
២៥	**សោម សារិទ្ធ**	ប	០១-០២-១៩៧២	មន្ត្រីបច្ចេកទេសមធ្យម	ថ្នាក់លេខ **១៤**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ					
តាំងស៊ប់ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១២ តទៅ					
១	**លឹម មាលា**	ស	០២-០៩-១៩៨៥	មន្ត្រីបច្ចេកទេសមធ្យម	ថ្នាក់លេខ ១៤

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១១៦៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
